គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**មតិស្វាគមន៍ និងរបាយការណ៍សង្ខេប**

ដោយ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍
គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

ក្នុង **"ទិវាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស លើកទី៩ ឆ្នាំ២០២៥"**

ក្រោម**ប្រធានបទ** ៖ «សុខដុមនីយកម្មសាសនានៅកម្ពុជា ជាសក្តានុពលក្នុងការប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់នាសម័យបច្ចេកវិទ្យា»

*ថ្ងៃពុធ ១១រោច ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩*
*ត្រូវនឹងថ្ងៃទី ២០ ខែសីហា ឆ្នាំ២០២៥*
*នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍អន្តរជាតិជ្រោយចង្វារ (OCIC)*

---

- សូមក្រាបថ្វាយបង្គំ សម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ សម្តេចព្រះសង្ឃនាយក សម្តេចព្រះសង្ឃនាយករង ព្រះរាជាគណៈ ព្រះមន្ត្រីសង្ឃ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីគោរពសក្ការៈ
- សូមគោរព **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និង**លោកជំទាវ កែ សួនសុភី ស សុខា** ជាទីគោរពដ៏ខ្ពង់ខ្ពស់
- សូមគោរពសម្តេច ឯកឧត្តម លោកជំទាវ សមាជិក សមាជិកា ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល
- សូមគោរព ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត កុងស៊ុល និងតំណាងស្ថានបេសកកម្មនានាប្រចាំនៅព្រះរាជាណាចក្រកម្ពុជា
- សូមគោរព គណៈដឹកនាំជាន់ខ្ពស់ នៃសាសនាឥស្លាមកម្ពុជា និងមេដឹកនាំជាតំណាងនិកាយនានា នៃសាសនាគ្រឹស្ត នៅកម្ពុជា
- ប្រធាន និងតំណាង អង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការសង្គមស៊ីវិល
- ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាលរាជធានីខេត្ត
- តំណាងគ្រប់និកាយសាសនា និងបងប្អូនជនរួមជាតិទាំងអស់ ជាទីស្រឡាញ់រាប់អាន !

ជាបឋម ក្នុងនាមគណៈកម្មការរៀបចំទិវាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (**គ.ជ.ប.ជ**) ខ្ញុំព្រះករុណាខ្ញុំម្ចាស់ មានសេចក្តីសោមនស្សរីករាយឥតឧបមា ចំពោះវត្តមានដ៏ខ្ពង់ខ្ពស់ និងមានតម្លៃ របស់ **ឯកឧត្តមអគ្គបណ្ឌិត**

**ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងលោកជំទាវ ដែលជាតំណាងដ៏ខ្ពង់ខ្ពស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត** ដែលបានឆ្លៀតឱកាសដ៏មានតម្លៃ ផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់ អញ្ជើញជាអធិបតីក្នុងពិធី **ទិវាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស** នាថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៥ នេះ ដែលញ៉ាំងឱ្យពិធីនេះ រឹងរឹតតែមានអត្ថន័យ ប្រសើរថ្លៃថ្លា ទ្វេឡើងទៀត។ ខ្ញុំព្រះករុណា ខ្ញុំម្ចាស់ ក៏សូមថ្លែងនូវអំណរព្រះគុណ ថ្វាយ ប្រគេន សម្តេច..........ជាអម្ចាស់ ព្រះមន្ត្រីសង្ឃជាន់ខ្ពស់ នៃគណៈមហានិកាយ និងធម្មយុត្តិកនិកាយ ព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ និងសូមថ្លែងអំណរគុណ ចំពោះគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមជាន់ខ្ពស់ ជាតំណាង សាសនាឥស្លាមទាំងពីរនិកាយ មេដឹកនាំជាតំណាងសាសនាគ្រីស្ទ ទាំងបីនិកាយ ឯកឧត្តម លោកជំទាវ អង្គទូត និងស្ថានតំណាងនៃបណ្តាប្រទេសជាមិត្ត ឯកឧត្តម លោកជំទាវ ជាឥស្សរជនជាន់ខ្ពស់ នៃស្ថាប័នជាតិ ជាអធិបតី និងវត្តមានយ៉ាងច្រើនកុះករពីសំណាក់ភ្ញៀវជាតិ និងអន្តរជាតិ ទាំងអស់ ដែលបានអញ្ជើញចូលរួមក្នុងកម្មវិធីជាតិ ដ៏មានសារៈសំខាន់នេះ ប្រមាណ **២.០០០ អង្គ/នាក់** ដែលនេះជាការបង្ហាញនូវស្មារតីសាមគ្គីឯកភាពជាធ្លុងមួយ ប្រកបដោយឆន្ទៈដ៏មុះមុត ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** នាងខ្ញុំសូមការអនុញ្ញាតធ្វើសេចក្តីរាយការណ៍សង្ខេប អំពីនូវខ្លឹមសារ នៃកម្មវិធីស្ថានភាពនៃអំពើជួញដូរមនុស្ស និងកិច្ចខិតខំប្រឹងប្រែងក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់រាជរដ្ឋាភិបាល ដៃគូពាក់ព័ន្ធ និងវិស័យសាសនានៅកម្ពុជា ដូចខាងក្រោម៖

ជាបឋម ខ្ញុំព្រះករុណាខ្ញុំម្ចាស់ នាងខ្ញុំ សូមសម្តែងនូវការគោរពដឹងគុណចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលបាន និងកំពុងតែបន្តយកចិត្តទុកដាក់ចំពោះសុវត្ថិភាពប្រជាពលរដ្ឋ ដែលកំពុងរងនូវហានិភ័យពីគ្រោះមហន្តរាយដែលបង្កឡើងដោយកត្តាធម្មជាតិ និងកត្តាមនុស្ស ជាពិសេសអំពើជួញដូរ និងកេងប្រវ័ញ្ចលើមនុស្សគ្រប់ទម្រង់ ដែលក្នុងឱកាសនេះ គឺជាយុទ្ធនាការដ៏ធំមួយ ដែលត្រូវបានរៀបចំឡើង ដើម្បីផ្សព្វផ្សាយ បំផុសស្មារតី ដល់ថ្នាក់ដឹកនាំ និងប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន ឱ្យរួមគ្នាបង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់ទម្រង់ ដែលបាន និងកំពុងធ្វើឱ្យមនុស្សរងទុក្ខ បាត់បង់ភាពជាមនុស្ស និងទទួលរងនូវការកេងប្រវ័ញ្ចពីឧក្រិដ្ឋជនយ៉ាងសាហាវឃោរឃៅ នៅក្នុងប្រទេស ក្នុងតំបន់ និងក្នុងពិភពលោក។ ទិវាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស ឆ្នាំ២០២៥ នេះ គឺត្រូវបានរៀបចំឡើង ក្រោម **ប្រធានបទ** “ សុខដុមនីយកម្មសាសនានៅកម្ពុជា ជាសក្តានុពលក្នុងការប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់លើមនុស្ស នាសម័យបច្ចេកវិទ្យា “ ។

**សម្តេច ព្រះថេរានុត្ថេរៈ ជាទីគោរពសក្ការៈ ឯកឧត្តម លោកជំទាវ គណៈអធិបតី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ជាទីគោរពរាប់អាន !**

ឆ្នាំ២០២៥ គឺជាឆ្នាំដែលព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាពិភពលោក បាន និងកំពុងរងនូវវិបត្តិយ៉ាងធ្ងន់ធ្ងរ។ ប្រទេសជាច្រើន ទទួលរងនូវគ្រោះមហន្តរាយដែលបង្កពីធម្មជាតិដ៏អាក្រក់ រួមទាំងគ្រោះរញ្ជួយដី ទឹកជំនន់ ខ្យល់ព្យុះ អគ្គីភ័យ រលកយក្ស ដែលបានបំផ្លិចបំផ្លាញជីវិតមនុស្ស សត្វ និងបរិស្ថានរស់នៅច្រើនឥត

គណនា។ ដោយឡែកវិបត្តិសង្គម ដែលបង្ករឡើងដោយជម្លោះប្រដាប់អាវុធ និងសង្គ្រាមបង្ហូរឈាម ក៏ត្រូវបាន កើតឡើងជាបន្តបន្ទាប់ និងរាលដាលពីតំបន់មួយទៅតំបន់មួយ ដែលធ្វើឱ្យប្រទេសដែលធ្លាប់តែមានទំនាក់ទំនងល្អជាមួយគ្នា បែរជាប្រឈមមុខដាក់គ្នា លែងមានកិច្ចសហការ និងយោគយល់គ្នា ជាក់ស្តែង កម្ពុជាកំពុងទទួលរងគ្រោះយ៉ាងធ្ងន់ធ្ងរ ដោយមិននឹកស្មានដល់ ថាសូម្បីតែប្រទេសភូមិផងរបងជាមួយ ក៏មានតែការប្រកួតប្រជែង ហួតដល់មានការរំលោភឈ្លានពានគ្នា វាយប្រហារគ្នាដោយឥតកោតក្រែង បំផ្លាញអាយុជីវិតមនុស្ស សម្បត្តិវប្បធម៌ ដោយឥតស្តាយស្រណោះ តាមរយៈការប្រើអាវុធធុនធ្ងន់ គ្រាប់ផ្លោង ទម្លាក់គ្រាប់បែក ប្រើផ្សែងពុល បំផ្លាញជីវិតប្រជាជនស្លូតត្រង់ដោយឥតរើសមុខ បង្កើតជាមហន្តរាយដ៏ធំធេង និងមានផលប៉ះពាល់យូរអង្វែងដល់ការរស់នៅរបស់មនុស្ស សត្វ និងធម្មជាតិ។ ទង្វើទាំងនេះ អាចកើតមានឡើងបាន អាស្រ័យដោយមនុស្សខ្វះសីលធម៌ មនុស្សធម៌ អាត្មានិយម ឈ្នានីស ព្យាបាទ មិនឱ្យអ្នកដទៃបានសុខ មានតែភាពវឹកវរ ចលាចល មិនឈប់ឈរ ដែលធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេដ្ឋកិច្ចជាតិទាំងសងខាង និងសេដ្ឋកិច្ចជាសាកល ដោយមនុស្សគ្មានឱកាសក្នុងការប្រកបអាជីវកម្ម រៀនសូត្រ និងអភិវឌ្ឍខ្លួនឯង និងអភិវឌ្ឍជាតិ គ្រប់វិស័យតាមបំណងប្រាថ្នាឡើយ។ ក្នុងគ្រាដ៏លំបាកសម្រាប់ការរស់នៅរបស់មនុស្ស ដែលបាន និងកំពុងរងវិបត្តិ និងពោរពេញដោយការភ័យខ្លាច បានបង្កលក្ខណៈឱ្យឧក្រិដ្ឋជន ឆក់ឱកាសធ្វើសកម្មភាពបោកបញ្ឆោត អូសទាញមនុស្សឱ្យធ្លាក់ចូលក្នុងភាពរងគ្រោះដោយអំពើជួញដូរ និងធ្វើការកេងប្រវ័ញ្ចតាមគ្រប់រូបភាពបន្ថែមទៀត។

រាជរដ្ឋាភិបាលកម្ពុជា ដែលមានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាសេនាធិការ បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្សគ្រប់ទម្រង់។ យុទ្ធសាស្ត្រទាំងបួន គឺ (១). **ផ្តោតលើការបង្ការទប់ស្កាត់ (២).ការពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ (៣). កិច្ចការពារជនរងគ្រោះ និង (៤). ការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអន្តរជាតិ លើវិស័យច្បាប់ និងបទដ្ឋានគតិយុត្តនានា ដើម្បីឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស ដែលជាឧក្រិដ្ឋកម្មឆ្លងដែន**។

ក្នុងការងារបង្ការទប់ស្កាត់ វិស័យសាសនា បានដើរតួយ៉ាងសំខាន់ ក្នុងការផ្សព្វផ្សាយអប់រំ ពង្រឹងសតិ ស្មារតី ដល់មនុស្សគ្រប់វ័យ ឱ្យរឹងប៉ឹង តស៊ូ ព្យាយាម ជម្នះឧបសគ្គ និងចេះប្រុងប្រយ័ត្នស្មារតី មិនធ្លាក់ចូលទៅក្នុងឧបាយកល នៃជនល្មើស ដែលព្យាយាម អូសទាញមនុស្សទៅក្នុងភាពរងគ្រោះ ងាយស្រួលក្នុងការកេងប្រវ័ញ្ចគ្រប់រូបភាព។ តាមរយៈការអប់រំបែបសាសនា ធ្វើឱ្យមនុស្សកាត់បន្ថយនូវភាពភ្លើតភ្លើន លោភលន់ ចេះយល់អធ្យាស្រ័យ ចេះគោរព និងឱ្យតម្លៃ ដល់ជីវិតមនុស្ស ចេះចែករំលែក ផ្តល់ក្តីមេត្តា មិនរំលោភបំពានគ្នា និងផ្តល់ក្តីមេត្តា និងជួយគ្នាទៅវិញទៅមក។ នេះគឺជាមូលដ្ឋានគ្រឹះក្នុងការទប់ស្កាត់ និងលុបបំបាត់នូវទង្វើអសីលធម៌ ទាំងឡាយដែលជាការជួញដូរ កេងប្រវ័ញ្ច និងរំលោភបំពានលើមនុស្សផងគ្នា ហើយផ្តល់នូវសេចក្តីសុខឱ្យគ្នាទៅវិញទៅមក។

ការបង្ការទប់ស្កាត់ ត្រូវបានធ្វើឡើងតាមវិធីសាស្ត្រជាច្រើន រួមទាំងការអប់រំផ្ទាល់ ការផ្សព្វផ្សាយអប់រំតាមវេទិកាសាធារណៈ ក្នុងគោលនយោបាយភូមិ ឃុំ-សង្កាត់ មានសុវត្ថិភាព សិក្ខាសាលា វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយសាធារណៈ និងឯកជន និងយុទ្ធនាការថ្នាក់ជាតិ ដែលបន្ត

ទៅថ្នាក់ក្រោមជាតិ រួមមាន ទិវាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស និងទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ជាដើម ដែលធ្វើឱ្យមនុស្សគ្រប់វ័យ នៅទូទាំងប្រទេស រាប់លាននាក់បានយល់ដឹងកាន់តែច្បាស់ អំពីអំពើជួញដូរមនុស្ស កលល្បិចជនល្មើស វិធានការច្បាប់ និងវិធីបង្ការទប់ស្កាត់ និងចេះការពារខ្លួនពី បទល្មើស និងភាពរងគ្រោះ ដោយអំពើជួញដូរមនុស្ស។ លើសពីនេះទៅទៀត នៅមានវិធីសាស្រ្តបង្ការទប់ស្កាត់តាមជំនាញ នៅគ្រប់វិស័យ ដែលជាវិធីសាស្រ្តកាត់បន្ថយ កត្តាជំរុញ និងអូសទាញមនុស្ស ឱ្យធ្លាក់ចូលក្នុងភាពរងគ្រោះ យ៉ាងមានប្រសិទ្ធភាព ។

អគ្គនាយកដ្ឋានអន្តោប្រវេសន៍ក្រសួងមហាផ្ទៃ បានចូលរួមដាក់វិធានការទប់ស្កាត់សកម្មភាព ដែលសង្ស័យថាពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ដោយពិនិត្យ សង្កេត លើគំរុយដែលគួរសង្ស័យ ចំពោះជនមួយចំនួនដែលឆ្លងកាត់តាមច្រកទ្វារអន្តរជាតិ ដើម្បីកំណត់សញ្ញាណនៃជនសង្ស័យជាមេខ្យល់ ឬជាជនល្មើស ជួញដូរមនុស្ស ឬ ជាជនងាយរងគ្រោះ ដែលចាំបាច់ត្រូវធ្វើការទប់ស្កាត់ជាបន្ទាន់។ ក្នុងនេះ មន្រ្តីច្រកទ្វារអន្តរជាតិ បានរកឃើញ និងឃាត់ខ្លួនអ្នកដំណើរជនជាតិខ្មែរ ដើម្បីបង្ការទប់ស្កាត់ការចាញ់បោកការអូសទាញរបស់មេខ្យល់ជួញដូរមនុស្សដើម្បីកេងប្រវ័ញ្ចនៅក្រៅប្រទេស បានជាង ១០០ករណី។

ទន្ទឹមនឹងនោះ ជនបរទេសមួយចំនួន ដែលត្រូវបានរកឃើញថាបានចូលមកស្នាក់នៅ និងធ្វើសកម្មភាពខុសច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ក៏ត្រូវបានបណ្តេញចេញ *ចំនួន ៤៨១ លើក មានមនុស្ស* **៥.៨៩៩** នាក់ មាន **៤៥** សញ្ជាតិ ។

វិធានការដ៏មុតស្រួច របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានគណៈកម្មការចំពោះកិច្ចប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា (Online Scams)** បានជំរុញឱ្យកម្លាំងសមត្ថកិច្ចទាំងថ្នាក់ជាតិ និងរាជធានី-ខេត្តទូទាំងប្រទេស ចុះបង្ក្រាបព្រមៗគ្នា រាល់ទីតាំងដែលសង្ស័យថាមានបង្កប់សកម្មភាពឆបោក តាមប្រព័ន្ធអនឡាញ យ៉ាងសកម្ម ជាបន្តបន្ទាប់ដូចភ្លៀងរលឹម ដើម្បីបោសសម្អាតបទល្មើសឆបោកតាមអនឡាញ យ៉ាងមានប្រសិទ្ធភាព ដើម្បីបង្កើតលំហសុវត្ថិភាពកាន់តែទូលំទូលាយ សម្រាប់ការរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជា និងជនបរទេសដែលស្នាក់នៅ ធ្វើការប្រកបអាជីវកម្ម និងធ្វើដំណើរកំសាន្ត នៅកម្ពុជា ដោយសប្បាយរីករាយ និងគ្មានការភ័យបារម្ភ។

តាមរបាយការណ៍ពីក្រុមការងារអនុវត្តច្បាប់ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិក្រសួងមហាផ្ទៃ ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត និងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានតាមដានស្រាវជ្រាវបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបចំនួន **៩៩ករណី** ប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៤ គឺ ថយចុះ **០៥ករណី** ស្មើនឹង **៤.៨០%** ៖

❖ **ករណីអំពើជួញដូរមនុស្ស**

បង្ក្រាបបាន **២៧/២២ករណី** (កើន ០៥ករណី) ឃាត់ខ្លួនជនសង្ស័យ ៣៧នាក់ (ស្រី ០៤នាក់)។ សង្គ្រោះជនរងគ្រោះ៖ ៨១នាក់(ស្រី ២១នាក់) មានអាយុក្រោម១៥ឆ្នាំ ០៥នាក់ (ស្រី ០២នាក់ អាយុ១៥-១៧

ឆ្នាំ ០៩នាក់ (ស្រី ០២នាក់) អាយុ១៨ឆ្នាំឡើង ៦៧នាក់(ស្រី ១៧នាក់) (បញ្ជូនទៅសង្គមកិច្ច ១១នាក់ ទៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍ដើម្បីធ្វើមាតុភូមិនិវត្តន៍ ៣០នាក់ និងទៅគ្រួសារ ៤០នាក់)។

❖ **ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ**

បង្ក្រាបបាន **៧២/៨២ករណី** (ថយចុះ ១០ករណី) ឃាត់ខ្លួនជនសង្ស័យ ៩៣នាក់(ស្រី ១៩នាក់) ជនជាតិវៀតណាម ០១នាក់ និងជនជាតិចិន ០៦នាក់។ សង្គ្រោះជនរងគ្រោះ ១៩៧នាក់(ស្រី១៩២នាក់) មានអាយុក្រោម១៥ឆ្នាំ ៦៨នាក់(ស្រី ៦៧នាក់) អាយុ១៥-១៧ឆ្នាំ ៧៨នាក់(ស្រី ៧៨នាក់) អាយុ១៨ឆ្នាំឡើង ៥១នាក់(ស្រី ៤៧នាក់) និងបានបញ្ជូនទៅមន្ទីរសង្គមកិច្ច ១៣៨នាក់ និងគ្រួសារ ៥៩នាក់។

❖ **ចំពោះចំណាត់ការផ្តន្ទាទោស**

<u>ចៅក្រមជំនុំជម្រះ នៃសាលាដំបូងរាជធានី-ខេត្ត បានសម្រេចក្តី</u> **សរុបចំនួន ២៣៦សំណុំរឿង ក្នុងនោះ សំណុំរឿងចាស់ ១១៨ និងសំណុំរឿងថ្មី ១១៨ ៖**

- **បានផ្តល់យុត្តិធម៌ជូនជនរងគ្រោះសរុបមានចំនួន ២៤៣នាក់(ស្រី២១១**នាក់) ក្នុងនោះ នីតិជនចំនួន **៧៦**នាក់(ស្រី **៦១**នាក់) អនីតិជន **១៥១**នាក់(ស្រី**១៤៦**នាក់) និងជនបរទេស **១៦**នាក់(ស្រី**០៤**នាក់)។
- **ជនជាប់ចោទ**សរុបមានចំនួន **៣៥៤**នាក់(ស្រី **៤៧**នាក់) ក្នុងនោះ នីតិជនសរុបចំនួន **២៦៨**នាក់(ស្រី **៤៥**នាក់) អនីតិជន **៤០**នាក់(ស្រី**០២**នាក់) និងជនបរទេស **៤៦**នាក់(ស្រី**០០**នាក់) ដោយសម្រេចដាក់ឱ្យជាប់ពន្ធនាគារ **១០១**នាក់ **ស្រី ១០នាក់** ។

❖ **ក្នុងកិច្ចការពារជនរងគ្រោះ** ក្រុមការងារកិច្ចការពារជនរងគ្រោះ ដឹកនាំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានសហការជាមួយក្រសួង មន្ទីរ អង្គភាពពាក់ព័ន្ធ ជាពិសេស ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងកងរាជអាវុធហត្ថ ក្នុងការទទួលយកជនរងគ្រោះ និងអ្នកដែលសង្ស័យ ថាបានរងគ្រោះ ដោយអំពើជួញដូរមនុស្ស ទាំងនៅក្នុងប្រទេស និងពីប្រទេសពាក់ព័ន្ធ សរុបចំនួន **២០៣នាក់** (ប្រុស ១៣នាក់ ស្រី ១៤២នាក់ កុមារា ០៧នាក់ កុមារី ៤១នាក់)។ បន្ទាប់ពីបានកំណត់អត្តសញ្ញាណដោយមន្ត្រីនគរបាលយុត្តិធម៌រួចហើយ កំណត់បានថា ជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស **១៩៤**នាក់ (ប្រុស ១២នាក់ ស្រី ១៣៦នាក់ កុមារា ០៧នាក់ កុមារី ៣៩នាក់) និងសហការជាមួយអង្គការដៃគូដើម្បីសហការបន្តផ្តល់សេវាជូនជនរងគ្រោះ មាន អង្គការការីតាសកម្ពុជា ៣៩នាក់ អង្គការរតនៈអ៊ីនធឺណេសិនណល ៦៤នាក់ អង្គការមូលនិធិហាការអន្តរជាតិ ១៦នាក់ អង្គការសម្ព័ន្ធចាប់ដៃ ១១នាក់ អង្គការCWCC ១៦នាក់ អង្គការIJM ០១នាក់ អង្គការម៉ារីសុី០៩នាក់ អង្គការអាដហុក ០៧នាក់ អង្គការតំណក់ទឹក ០១នាក់ ។

លើសពីនេះទៅទៀត ក្រុមការងារកិច្ចការពារជនរងគ្រោះ បានធ្វើសមាហរណកម្ម ជនរងគ្រោះ និងជនដែលសង្ស័យថារងគ្រោះ ឱ្យត្រឡប់ទៅសហគមន៍វិញដោយសុវត្ថិភាព ចំនួន **៩២នាក់** (ប្រុស ០២នាក់ ស្រី **៧៩**នាក់ និងកុមារី **១១**នាក់ ព្រមទាំងបានធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះជាបរទេសទៅប្រទេសដើមវិញ

សរុបចំនួន **០៧**នាក់ (ស្រី **០២**នាក់) ជនជាតិ ឥណ្ឌា ០២នាក់ ស្រីលង្កា ០២នាក់ វៀតណាម ០២នាក់ និង ជនជាតិចិន ០១នាក់ ។

**សម្តេច ឯកឧត្តម លោកជំទាវ លោកលោកស្រី !**

អ្វីដែលជាការគួរឱ្យកត់សម្គាល់ ដែលកើតមានឡើងក្នុងឆ្នាំ២០២៥ នេះ គឺការកើតឡើងនូវទង្វើអមនុស្សធម៌ ទៅលើពលករកម្ពុជាដែលបាន និងកំពុងរស់នៅ និងធ្វើការយ៉ាងសកម្ម នៅក្នុងប្រទេសថៃ ក្រោយពីមានបញ្ហាជម្លោះប្រដាប់អាវុធនៅព្រំដែន កម្ពុជា ថៃ និងឈានដល់សង្គ្រាមគម្រាមកំហែងសុវត្ថិភាពប្រជាពលរដ្ឋ បានធ្វើឱ្យប្រជាពលរដ្ឋនាំគ្នាភៀសខ្លួនមកនៅក្នុងជំរំភៀសសឹក ប្រមាណជិតម្ភៃម៉ឺននាក់។ នៅឯប្រទេសថៃឯណោះវិញ ពលករដែលបាន និងកំពុងស្នាក់នៅ និងធ្វើការទីនោះ បានទទួលរងការព្រមាន ការប្រមាថមាក់ងាយ ការរើសអើង កេងប្រវ័ញ្ច ការប្រើអំពើហិង្សា បណ្តេញចេញ យ៉ាងអាណោចអធម ដែលធ្វើឱ្យពលករបង្ខំចិត្ត ត្រូវចាកចេញពីប្រទេសថៃ និងវិលត្រឡប់មកមាតុភូមិកម្ពុជាវិញ យ៉ាងច្រើនកុះករតាមច្រកព្រំដែន ជាពិសេសច្រកដូង ក្នុងស្រុកកំរៀង ខេត្តបាត់ដំបង ច្រកប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងមួយចំនួន ចេញតាមច្រកព្រំខេត្ត ប៉ៃលិន និងច្រកអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាដើម។ គ្រាន់តែរយៈពេល ត្រឹមប្រាំសប្តាហ៍ចុងក្រោយនេះ ចំនួនប្រជាពលរដ្ឋដែលជាង ៧០% ជាពលករ បានវិលត្រឡប់មកវិញ ជាង ៩០ម៉ឺននាក់ រួចហើយ។ ការវិលត្រឡប់នេះ ក៏ត្រូវបានធ្វើឡើងដោយលំបាក ពោរពេញដោយការភ័យខ្លាច និងរំខាន ដោយមិនមានគិតគូរពីបញ្ហាមនុស្សធម៌ ចំពោះស្ត្រីមានផ្ទៃពោះ កូនតូច ជនចាស់ជរា ឬមានជំងឺ មានពិការភាព អ្វីឡើយ។ ស្ថានភាពទាំងនេះ គឺ បណ្តាលមកពីទង្វើអសីលធម៌ អមនុស្សធម៌ និងមិនគោរពសិទ្ធិមនុស្ស ដែលពលករមិនអាចស៊ូទ្រាំ នឹងទទួលយកបាន។ ក្នុងស្ថានភាពដ៏លំបាកនេះ រាជរដ្ឋាភិបាលកម្ពុជា ចាំបាច់ត្រូវទទួលរ៉ាប់រងក្នុងការទទួលដោះស្រាយ ជីវភាព ការអប់រំ ស្តារនីតិសម្បទា កាត់បន្ថយវិបត្តិផ្លូវចិត្តរបស់ពលករ ព្រមទាំងបង្កើត និងបង្កើនការងារ មុខរបរ អាជីវកម្ម សេវាកម្ម ជូនប្រជាពលរដ្ឋ ជាពិសេស ពលករដែលវិលត្រឡប់ តាមកម្រិតនៃសេចក្តីត្រូវការ ឱ្យបានទាន់ពេលវេលា ដើម្បីបញ្ចៀសឱ្យបាន នូវភាពប្រថុយប្រថាន តាមការអូសទាញរបស់ជនល្មើស ដែលនាំឱ្យរងគ្រោះ ជាថ្មី ដោយអំពើជួញដូរ កេងប្រវ័ញ្ច និងរំលោភបំពាន ដោយអមនុស្សធម៌។

អាស្រ័យដោយបរិយាកាសដែលជានានូវសុវត្ថិភាព និងសន្តិសុខសម្រាប់អាជីវកម្ម កម្ពុជានៅមានឱកាសច្រើនសម្រាប់អ្នកវិនិយោគ ដែលតាមរបាយការណ៍របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) មានក្រុមហ៊ុនវិនិយោគបរទេសដែលបានចុះបញ្ជីមានចំនួនសរុប **៣.៥១៦** ក្រុមហ៊ុន ដែលមានម្ចាស់អាជីវកម្ម ពី៤៥សញ្ជាតិ ប្រៀបធៀបនឹងឆ្នាំ២០២៤ កើនឡើងចំនួន **១៥៦**ក្រុមហ៊ុន ស្មើ ៤,៦៤% ក្នុងនោះរួមមាន វិស័យរោងចក្រ សហគ្រាស **២.៩៦៦** ក្រុមហ៊ុន វិស័យកសិកម្ម **២៦១**ក្រុមហ៊ុនវិស័យទេសចរណ៍ **១២៧**ក្រុមហ៊ុន និងវិស័យហេដ្ឋារចនាសម្ព័ន្ធ **១៦២** ក្រុមហ៊ុន ដែលបានផ្តល់ការងារដល់ពលករបរទេសនិងខ្មែរ សរុប **៣.៥៨៣.៧៣៨** កន្លែង ។

កម្ពុជា នៅតែបន្តពង្រឹងកិច្ចសហការជាមួយបណ្តាប្រទេសក្នុងតំបន់ និងជាអន្តរជាតិ ដើម្បីរួមគ្នាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ និងខិតខំកំណត់រកវិធីសាស្ត្រ ក្នុងការលុបបំបាត់ឫសគល់នៃបញ្ហា បង្កើនការដោះស្រាយភាពស្មុគស្មាញទាំងឡាយ ដោយសន្តិវិធី និងដោយបញ្ចៀសនូវភាពប្រឈមទាំងឡាយឱ្យបានជា

អតិបរមា និងសង្ឃឹមថា បណ្តាប្រទេសទាំងអស់ក្នុងតំបន់ នៅតែបន្តការប្តេជ្ញាចិត្តខ្ពស់ ក្នុងការរួមគ្នាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នេះ ឱ្យមានជោគជ័យ ។

ជាចុងក្រោយ ក្នុងនាមអង្គពិធីទាំងមូល ខ្ញុំសូមឱ្យការឧទ្ទិសបួងសួងក្នុងទិវាជាតិអន្តរសាសនា នាពេលនេះ កើតបានជាកុសលផលបុណ្យជូនដល់វិញ្ញាណក្ខន្ធ វីរយុទ្ធជន វីរនគរបាល និងប្រជាពលរដ្ឋ ដែលបានបាត់បង់ជីវិតក្នុងសង្គ្រាមដ៏ជូរចត់ កន្លងទៅនេះ សូមឱ្យបានទៅកាន់សុគតិភព និងទទួលបាននូវភាពស្ងប់សុខ ក្នុងជាតិកំណើតថ្មីក្នុងសុគតិភព និងសូមបន់ស្រន់ដល់ព្រះពុទ្ធ ព្រះអឡោះ ព្រះយេស៊ូ ជាម្ចាស់ ទេវតា និងវត្ថុស័ក្តិសិទ្ធិដ៏មានឫទ្ធិទាំងឡាយក្នុងលោក សូមប្រទានពរឱ្យពិភពលោក បានស្រស់ថ្លាឡើងវិញ គ្រប់ទីកន្លែង មនុស្សទាំងឡាយបានក្តីសុខរួចផុតគ្រោះមហន្តរាយ និងទុក្ខភ័យទាំងឡាយ ដែលបណ្តាលពីគ្រោះធម្មជាតិ ជំងឺឆ្លងដែលកាចសាហាវផងទាំងពួង សូមពិភពលោកឱ្យមានសន្តិភាព ស្ងប់សុខ គ្មានសង្គ្រាមបំផ្លាញគ្នា និងសូមឱ្យអំពើទុច្ចរិតដែលបង្កវិនាសកម្មលើមនុស្សផងគ្នា ដោយអំពើជួញដូរ និងកេងប្រវ័ញ្ចលើមនុស្សក្តី និងដោយការប្រព្រឹត្តអំពើដ៏សាហាវឃោរឃៅ ដទៃទៀតក្តី ឱ្យវិនាសសាបសូន្យទៅកុំបីមានសេសសល់ឡើយ។

សូមថ្វាយ និងប្រគេនពរ ដល់សម្តេច ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ **ឯកឧត្តមអតិសន្តិបណ្ឌិត និងលោកជំទាវ** មេដឹកនាំ និងសាសនិកគ្រប់សាសនា នៅកម្ពុជា ឯកឧត្តម លោកជំទាវគណៈអធិបតី ឯកឧត្តម លោកជំទាវ លោក លោកស្រី យុវជន យុវនារី អង្គពិធីទាំងមូល សូមបានប្រកបដោយពុទ្ធពរ និងពរព្រះជាម្ចាស់ គ្រប់ប្រការ កុំបីឃ្លៀងឃ្លាតឡើយ៕

**សូមអរព្រះគុណ សូមអរគុណ** !